# សង្ខេបប្រតិបត្តិ

## ក្របខណ្ឌធ្វើផែនការអភិវឌ្ឍន៍ជនជាតិដើមភាគតិច

**INDIGENOUS PEOPLES PLANNING FRAMEWORK (IPPF)**

សេចក្តីសង្ខេបប្រតិបត្តិនេះរំលេចឡើងនូវចំណុចគោលសំខាន់ៗនៃគម្រោង "ក្របខណ្ឌធ្វើផែនការអភិវឌ្ឍន៍ជនជាតិដើមភាគតិច" (តទៅហៅកាត់ថា IPPF) ដែលត្រូវបានរៀបចំឡើងដោយក្រសួងអភិវឌ្ឍន៍ជនបទ។ ក្របខណ្ឌនេះនឹងអនុវត្តលើសកម្មភាពទាំងឡាយនៅក្រោមដំណាក់កាលទីពីរនៃគម្រោងសម្រាប់ប្រទេសកម្ពុជា ស្តីពី "ការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយក្នុងតំបន់អាស៊ីអាគ្នេយ៍" (តទៅហៅកាត់ថា KH-SEADRM II)។ ក្របខណ្ឌនេះជាឯកសាររស់ ដែលអាចត្រូវធ្វើបច្ចុប្បន្នភាពស្របតាមភាពចាំបាច់នៅក្នុងអំឡុងពេលនៃការអនុវត្តគម្រោងនេះ។

### សេចក្តីអធិប្បាយសង្ខេបរបស់គម្រោង

ជំពូកទី១ រៀបរាប់អំពីគោលបំណងរបស់គម្រោង KH-SEADRM II ដែលសំដៅជួយដល់ការសាងសង់ឡើងវិញនូវហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនជនបទ ដែលរងការខូចខាតដោយសារទឹកជំនន់ក្នុងឆ្នាំ២០២០។ គម្រោងនេះនឹងជួយផងដែរដល់កិច្ចខិតខំរបស់រដ្ឋាភិបាល នៅក្នុងការបញ្ជ្រាបរាល់ទិដ្ឋភាពពាក់ព័ន្ធការគ្រប់គ្រងគ្រោះមហន្តរាយ ទៅក្នុងយុទ្ធសាស្រ្តជាតិបង្កើនភាពធន់នៃប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន ទៅនឹងគ្រោះមហន្តរាយ។ គម្រោង KH-SEADRM II នឹងផ្តល់ហិរញ្ញប្បទានដល់ការសាងសង់ឡើងវិញនូវផ្លូវ និងស្ពានជនបទ មានប្រវែងសរុបប្រហែលជា ២០០ ទៅ ៣០០គីឡូម៉ែត្រ ដោយក្នុងនោះវាផ្តោតទៅលើខេត្តជម្រើសចំនួនប្រាំពីរដែលរងផលប៉ះពាល់ពីទឹកជំនន់ គឺមាន ខេត្តបន្ទាយមានជ័យ, បាត់ដំបង, កំពង់ស្ពឺ, កំពង់ឆ្នាំង, ពោធិសាត់, សៀមរាប និង ត្បូងឃ្មុំ។ គោលបំណងរបស់ក្របខណ្ឌ IPPF រួមមាន៖

- ធានាឱ្យបាននូវការលើកស្ទួយនូវការគោរពពេញលេញចំពោះសិទ្ធិមនុស្ស, សេចក្តីថ្លៃថ្នូរ, សេចក្តីប្រាថ្នាចង់បាន, អត្តសញ្ញាណ, វប្បធម៌ និងរបបចិញ្ចឹមជីវិតអាស្រ័យលើធនធានធម្មជាតិរបស់សហគមន៍ជនជាតិដើមភាគតិច នៅក្នុងរាល់ដំណើរការរៀបចំផែនការ និង ការអនុវត្តក្រោមគម្រោង SEADRM II។
- បញ្ចៀសឱ្យបាននូវផលប៉ះពាល់ធ្ងន់ធ្ងរនៃគម្រោងទៅលើសហគមន៍ជនជាតិដើមភាគតិច។ ក្នុងករណីចៀសមិនបាន ចាំបាច់ត្រូវកាត់បន្ថយ ឬសម្រាលផលប៉ះពាល់ឱ្យកម្រិតអប្បបរមា ឬមួយត្រូវផ្តល់ការសងជំងឺចិត្តដល់សហគមន៍ដែលរងផលប៉ះពាល់។
- លើកកម្ពស់អត្ថប្រយោជន៍នៃការអភិវឌ្ឍប្រកបដោយចីរភាព ក៏ដូចជាឱកាសសម្រាប់សហគមន៍ជនជាតិដើមភាគតិច តាមរបៀបយ៉ាងណាដែលមានលក្ខណៈងាយទទួលបាន, មានភាពសមរម្យផ្នែកវប្បធម៌ និងមានភាពបរិយាបន្ន។
- កែលម្អឱ្យកាន់តែប្រសើរនូវការរៀបចំគម្រោង ហើយលើកកម្ពស់ឱ្យមានការគាំទ្ររបស់មូលដ្ឋានតាមរយៈការបង្កើត និងការរក្សាឱ្យមាននូវទំនាក់ទំនងជាប្រចាំឈរលើមូលដ្ឋាននៃការពិគ្រោះយោបល់គ្នាប្រកប

ដោយអត្ថន័យជាមួយសហគមន៍ជនជាតិដើមភាគតិច ដែលរងផលប៉ះពាល់ពីគម្រោង SEADRM II ក្នុងអំឡុងវគ្គនៃការអនុវត្តរបស់វា។

- ទទួលស្គាល់, គោរព និងរក្សាការពារវប្បធម៌, ចំណេះដឹង និងទម្លាប់អនុវត្តន៍របស់សហគមន៍ជនជាតិដើមភាគតិច ព្រមទាំងផ្តល់ឱ្យពួកគេនូវឱកាសសម្រាប់ធ្វើការទម្លាប់ខ្លួនទៅតាមលក្ខខណ្ឌប្រែប្រួលនានា ក្នុងរបៀបនិងក្របខណ្ឌពេលវេលាមួយដែលពួកគេចាត់ទុកថាសមស្របអាចទទួលយកបាន។

## ទិដ្ឋភាពរួមស្តីពីជនជាតិដើមភាគតិច

ជំពូកទី២ ផ្តល់ព័ត៌មានទូទៅអំពីជនជាតិដើមភាគតិចនៅក្នុងប្រទេសកម្ពុជា ក្នុងនោះមានទាំងទិដ្ឋភាពរួមស្តីពីជនជាតិដើមភាគតិចនៅក្នុងខេត្តគោលដៅទាំងប្រាំពីរ អមជាមួយនឹងការអធិប្បាយអំពីលក្ខណសម្បត្តិផ្នែកសេដ្ឋកិច្ច-សង្គម និងវប្បធម៌ របស់ក្រុមជនជាតិដើមភាគតិចសំខាន់ៗ ដែលមានវត្តមាននៅក្នុងខេត្តទាំងនោះផងដែរ។

## ក្របខណ្ឌច្បាប់

ជំពូកទី៣ រំលេចអំពីមូលដ្ឋានច្បាប់សម្រាប់យកមករៀបចំបង្កើតគម្រោង IPPF។ គម្រោងនេះត្រូវបានរៀបចំឡើងដោយឈរលើមូលដ្ឋានច្បាប់ និងបទប្បញ្ញត្តិជាតិពាក់ព័ន្ធជនជាតិដើមភាគតិច និងលើមូលដ្ឋាននៃ ស្តង់ដាសង្គម និងបរិស្ថានទី៧របស់ធនាគារពិភពលោកស្តីពីជនជាតិដើមភាគតិច (World Bank's Environmental and Social Standard 7 on Indigenous Peoples/ESS7)។ ការវិភាគមួយត្រូវបានធ្វើឡើងជាការចាំបាច់ ដោយសារតែមានគម្លាតគ្នារវាងឯកសារគោលនយោបាយទាំងពីរនេះ។ ការវិភាគនេះបានរកឃើញថា ថ្វីដ្បិតតែមានចំណុចបំពេញឱ្យគ្នាទៅវិញទៅមកខ្លះរវាងច្បាប់និងបទប្បញ្ញត្តិរបស់កម្ពុជា និងគោលការណ៍ស្តង់ដា ESS7 របស់ធនាគារពិភពលោកក៏ដោយ គេមិនឃើញមានការចែងលម្អិតនូវបទប្បញ្ញត្តិ និងនីតិវិធីប្រតិបត្តិ សម្រាប់សម្រួលដល់ការអនុវត្តឱ្យមានប្រសិទ្ធភាពនូវផែនការសម្រាប់ជនជាតិដើមភាគតិច (Indigenous Peoples Plan/IPP) នៅឡើយទេ។ អាស្រ័យហេតុនេះ ក្របខណ្ឌ IPPF ស្នើឡើងនូវវិធានការមួយចំនួនក្នុងគោលដៅបំប្រួមគម្លាតនេះឱ្យកាន់តែតូចមកវិញ តាមរយៈកិច្ចពិគ្រោះយោបល់ជាមួយជនជាតិដើមភាគតិច និងដើម្បីធានាឱ្យបានថា ជនជាតិដើមភាគតិចរស់នៅក្នុងតំបន់អនុគម្រោងនឹងទទួលបានអត្ថប្រយោជន៍ផ្នែកសង្គមនិងសេដ្ឋកិច្ច ដែលមានលក្ខណៈសមស្របជាមួយវប្បធម៌របស់ពួកគេ។

## ហានិភ័យ, ផលប៉ះពាល់ និងវិធានការសម្រាល

ជំពូកទី៤ រៀបរាប់អំពីហានិភ័យ និងផលប៉ះពាល់ផ្នែកបរិស្ថាន និងសង្គម ដែលត្រូវបានកំណត់រកឃើញពាក់ព័ន្ធជាមួយសកម្មភាពសាងសង់របស់គម្រោង។ ជាការប្រមើលដោយផ្អែកលើលក្ខណៈធម្មជាតិ និងវិសាលភាពនៃការសាងសង់ឡើងវិញនៃផ្លូវ និងស្ពានក្រោមគម្រោងនេះ សកម្មភាពនានាដែលបានគ្រោងទុកមិនត្រូវបានរំពឹងថានឹងនាំឱ្យមានផលប៉ះពាល់ធ្ងន់ធ្ងរទៅលើជនជាតិដើមភាគតិចនៅក្នុងតំបន់គោលដៅឡើយ។ ពិតណាស់ ផលប៉ះពាល់ធ្ងន់ធ្ងរខ្លះត្រូវបានរំពឹងថានឹងកើតមាន តែក្នុងមួយរយៈពេលខ្លីទេ ដូចជាផលប៉ះពាល់ផ្នែកបរិស្ថាន មានសូររំខាន, ធូលីហុយ, ការញ្ញើយជាដើម នៅក្នុងដំណើរការសាងសង់ និងហានិភ័យផ្សេងទៀតពាក់ព័ន្ធជាមួយពលករ ដែលនឹងផ្លាស់ទីទៅកាន់តំបន់អនុគម្រោងដើម្បីផ្តល់ពលកម្មទ្រទ្រង់ដល់សកម្មភាពរបស់គម្រោង។ ការធ្វើលទ្ធកម្មដីធ្លីជាលក្ខណៈអចិន្ត្រៃយ៍គឺជាការចាំបាច់ចៀសមិនផុតទេ ប៉ុន្តែត្រូវបានរំពឹងថានឹងមានទ្រង់ទ្រាយតូច នៅតាមទីតាំងជាក់លាក់តែប៉ុណ្ណោះ។ ការធ្វើលទ្ធកម្មនេះវានឹងអាស្រ័យតាមភាពជាក់ស្តែង ថាតើផ្លូវមួយត្រូវសាងសង់ឡើងវិញលើគ្រឹះដែល

មានស្រាប់ ឬក៏ត្រូវពង្រីកទំហំទទឹង ឬត្រូវលើកកម្ពស់របស់វាទៅតាមចំណុចជាក់លាក់ ដើម្បីឆ្លើយតបទៅនឹងហានិភ័យដែលបណ្តាលមកពីទឹកជំនន់នាថ្ងៃអនាគត។ តាមការរំពឹងទុក ការធ្វើលទ្ធកម្មដីជាលក្ខណៈអចិន្ត្រៃយ៍ គឺទំនងជានឹងត្រូវធ្វើច្រើនជាងអត់ធ្វើ។ ដោយសារតែជនជាតិដើមភាគតិច (តាមការកំណត់និយមន័យក្នុងស្តង់ដា ESS7 របស់ធនាគារពិភពលោក) ច្រើនតែរស់នៅឆ្ងាយពីផ្លូវ និងស្ពានរបស់គម្រោង លទ្ធភាពមានតិចតួចណាស់សម្រាប់ផលប៉ះពាល់ (បណ្តាលមកពីការធ្វើលទ្ធកម្មដី ក៏ដូចជាផលប៉ះពាល់ផ្នែកបរិស្ថាន និងហានិភ័យផ្នែកសង្គម) អាចកើតមានឡើងចំពោះពួកគេ។

យ៉ាងណាក្តី ដើម្បីសម្រាលហានិភ័យ និងផលប៉ះពាល់នានា ក្របខណ្ឌ IPPF បានស្នើឡើងនូវវិធានការមួយចំនួនសម្រាប់បញ្ចៀសផលប៉ះពាល់ធ្ងន់ធ្ងរ។ នៅកន្លែងណាដែលមិនអាចចៀសបាន កិច្ចខិតខំត្រូវធ្វើជាចាំបាច់តាមរយៈការរៀបចំគម្រោងធ្វើផ្លូវដើម្បីកាត់បន្ថយផលប៉ះពាល់។ កាលណាអនុគម្រោងធ្វើផ្លូវ និងស្ពានត្រូវបានកំណត់ហើយបន្ទាប់មកទៀតគឺត្រូវធ្វើការផ្ទៀងផ្ទាត់មើលថាតើមានវត្តមានជនជាតិដើមភាគតិចឬទេ នៅក្នុងតំបន់អនុគម្រោង។ ប្រសិនបើមាន ការវាយតម្លៃផ្នែកសង្គមមួយចំគោលដៅ នឹងត្រូវបានធ្វើឡើង ដើម្បីធានាឱ្យមានការពិគ្រោះយោបល់ប្រកបដោយអត្ថន័យជាមួយសហគមន៍ជនជាតិដើមភាគតិច និងប្រមូលមតិតបរបស់គេពាក់ព័ន្ធហានិភ័យនិងផលប៉ះពាល់នៃអនុគម្រោង យកមកពិចារណានិងដាក់បញ្ចូលទៅក្នុងការរៀបចំរចនាគម្រោង និងទៅក្នុងការអនុវត្តអនុគម្រោង ផែនការគ្រប់គ្រងបរិស្ថាន និងសង្គម (Environmental and Social Management Plan)។ ផែនការសម្រាប់ជនជាតិដើមភាគតិច (IPP) មួយនឹងត្រូវបានរៀបចំបង្កើតឡើងដើម្បីធានាឱ្យបានថា សហគមន៍ជនជាតិដើមភាគតិចទទួលបានអត្ថប្រយោជន៍ផ្នែកសង្គមនិងសេដ្ឋកិច្ច ដែលមានលក្ខណៈសមស្របទៅនឹងវប្បធម៌របស់ខ្លួន ទោះបីជាពួកគេរងឬមិនរងផលប៉ះពាល់ធ្ងន់ធ្ងរពីគម្រោង ក៏ដោយ។

ជាផ្នែកមួយនៃកិច្ចការផ្ទៀងផ្ទាត់មើលនេះ បើផ្នែកណាមួយនៃសកម្មភាពគម្រោងមានសក្តានុពលបង្កផលប៉ះពាល់ធ្ងន់ធ្ងរទៅលើបូរណភាព និងផលិតភាពនៃដីធ្លីដែលជាកម្មសិទ្ធិរួមរបស់សហគមន៍ជនជាតិដើមភាគតិច ដីធ្លីនោះនឹងត្រូវយកមកពិនិត្យឱ្យបានល្អិតល្អន់ ហើយផាត់ចេញឱ្យនៅក្រៅវិសាលភាពគម្រោង។ ការងារស៊ីវិលនៃគម្រោងអាចធ្វើបាននៅក្បែរដីធ្លីជាកម្មសិទ្ធិរួមរបស់ជនជាតិដើមភាគតិច ប៉ុន្តែវាមិនត្រូវបង្កផលប៉ះពាល់ទៅលើបូរណភាព ឬ ផលិតភាពរបស់ដីធ្លីនោះទេ។ នៅក្រោមលក្ខខណ្ឌផាត់ចេញនេះ គោលការណ៍ស្តីពីការយល់ព្រមដោយសេរីក្រោយពីទទួលបានព័ត៌មានគ្រប់គ្រាន់ជាមុន (Free, Prior, Informed Concent/PIC) មិនអាចយកមកមកអនុវត្តបានទេសម្រាប់គម្រោងនេះ។

## ការរៀបចំផែនការសម្រាប់ជនជាតិដើមភាគតិច

ជំពូកទី៥ រៀបរាប់អំពីជំហាននានាដែលក្រសួងអភិវឌ្ឍន៍ជនបទត្រូវធ្វើសម្រាប់រៀបចំផែនការសម្រាប់ជនជាតិដើមភាគតិច។ ជំហានទាំងនោះរួមមាន នីតិវិធីផ្ទៀងផ្ទាត់រកមើលសហគមន៍ជនជាតិដើមភាគតិច, ការធ្វើការវាយតម្លៃផ្នែកសង្គមតាមគោលដៅនៅកន្លែងណាដែលមានជនជាតិដើមភាគតិច និងធាតុផ្សំដែលជាតម្រូវការចាំបាច់សម្រាប់ធ្វើផែនការសម្រាប់ជនជាតិដើមភាគតិច។ ជំពូកនេះក៏និយាយផងដែរអំពីថាតើភាគីពាក់ព័ន្ធគម្រោង ជាពិសេសសហគមន៍ជនជាតិដើមភាគតិចនៅក្នុងតំបន់អនុគម្រោង នឹងទទួលបានការចូលរួមដូចម្តេចខ្លះ នៅក្នុងពេលរៀបចំនិងអនុវត្តន៍អនុគម្រោង និងថាតើព័ត៌មានពាក់ព័ន្ធ មានដូចជាការពណ៌នាអំពីគម្រោង, ហានិភ័យនិងផលប៉ះពាល់ប

វិស្ថាននិងសង្គម, វិធានការសម្រាលផលប៉ះពាល់, និងយន្តការដោះស្រាយបណ្ដឹងតវ៉ាជាដើម ត្រូវបានលាតត្រដាងដូចម្ដេចខ្លះ សម្រាប់បម្រើគោលបំណងនៃការពិគ្រោះយោបល់ជាមួយសហគមន៍ជនជាតិដើមភាគតិច។

## យន្តការដោះស្រាយបណ្ដឹងតវ៉ា

ជំពូកទី៦ រំលេចឡើងអំពីយន្តការសម្រាប់ដោះស្រាយបណ្ដឹងតវ៉ា (GRM) ដែលគម្រោងត្រូវរៀបចំឡើងឱ្យមានជាស្រេចសម្រាប់បំពេញមុខងារឱ្យបានសមស្រប ដើម្បីធានាបានថាសហគមន៍ជនជាតិដើមភាគតិចដែលរងផលប៉ះពាល់ អាចរកវាបាន និងយកវាទៅប្រើបានដោយងាយនៅក្នុងការតវ៉ារបស់ខ្លួន។ គម្រោងក៏មានគោលដៅផងដែរក្នុងការធានាឱ្យបានថា បណ្ដឹងតវ៉ាដែលសហគមន៍ជនជាតិដើមភាគតិចលើកឡើង នឹងទទួលបានការដោះស្រាយទាន់ពេលវេលា និងប្រកបដោយប្រសិទ្ធភាព តាមរបៀបមួយដែលសមស្របទៅនឹងវប្បធម៌របស់ពួកគេ។ យន្តការ GRM ចែងសេចក្ដីណែនាំលម្អិតអំពីរបៀបដាក់ពាក្យតវ៉ា ក្នុងនោះមានទាំងទម្រង់បែបបទសម្រាប់ធ្វើពាក្យបណ្ដឹង, បណ្ដាញសម្រាប់បញ្ជូនពាក្យបណ្ដឹង និងដំណាក់កាលដែលត្រូវឆ្លងកាត់នៅក្នុងដំណើរការដោះស្រាយបណ្ដឹងតវ៉ា។ ជំពូកនេះរៀបរាប់ផងដែរអំពីកម្រិតពេលវេលាសម្រាប់ដំណាក់កាលនីមួយៗសម្រាប់ការទទួលដឹងឮបណ្ដឹងតវ៉ា និងការជូនដំណឹងទៅកាន់ម្ចាស់បណ្ដឹងវិញអំពីដំណើរការរកដំណោះស្រាយ និងសំណើដំណោះស្រាយ។

## ការរៀបចំចាត់ចែងការអនុវត្ត, ការតាមដាន និងការធ្វើរបាយការណ៍

ជំពូកទី៧ សង្កត់ធ្ងន់លើការទទួលខុសត្រូវរបស់ក្រសួងអភិវឌ្ឍន៍ជនបទ នៅក្នុងការអនុវត្តក្របខណ្ឌ IPPF នេះ។ ក្រសួងនឹងប្រាប់ធនាគារពិភពលោកឱ្យបានដឹង អំពីលទ្ធផលនៃការផ្ទៀងផ្ទាត់រកមើលសហគមន៍ជនជាតិដើមភាគតិចនៅក្នុងគោលដៅគម្រោង និងអំពីជំហានដែលក្រសួងត្រូវធ្វើ ក្នុងករណីដែលមានវត្តមានសហគមន៍ជនជាតិដើមភាគតិចនៅក្នុងតំបន់អនុគម្រោងណាមួយ។ កាលណារកឃើញថាមាន ក្រសួងអភិវឌ្ឍន៍ជនបទត្រូវជួលអ្នកពិគ្រោះយោបល់ផ្នែកជនជនដើមភាគតិច ឱ្យធ្វើការយ៉ាងជិតស្និទ្ធជាមួយក្រសួង ដើម្បីធ្វើការវាយតម្លៃផ្នែកសង្គមតាមគោលដៅក្នុងគម្រោង និងរៀបចំផែនការសម្រាប់ជនជាតិដើមភាគតិចពាក់ព័ន្ធនឹងករណីនោះ។ ការអនុវត្តអនុគម្រោងផែនការសម្រាប់ជនជាតិដើមភាគតិច នឹងស្ថិតនៅក្រោមការតាមដានផ្ទៃក្នុងរបស់ក្រសួងអភិវឌ្ឍន៍ជនបទ។ ផលប៉ះពាល់ធ្ងន់ធ្ងរទៅលើសហគមន៍ជនជាតិដើមភាគតិចដោយសារតែការធ្វើលទ្ធកម្មដីធ្លី (ប្រសិនបើមាន) នឹងត្រូវមានការពិនិត្យតាមដានពីសំណាក់អគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់គម្រោងនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងអភិវឌ្ឍន៍ជនបទ ស្របតាមគោលការណ៍ណែនាំរបស់ក្របខណ្ឌគោលនយោបាយដោះស្រាយផលប៉ះពាល់គម្រោង (Resettlement Policy Framework/RPF)។

## ចំណាយ និង ថវិកា

ជំពូកទី៨ បង្ហាញនូវថ្លៃចំណាយប៉ាន់ស្មានសម្រាប់ការអនុវត្តក្របខណ្ឌ IPPF និងប្រភពថវិកា ដែលនឹងបានមកពីមូលនិធិនៃសមភាគីគម្រោង និង ហិរញ្ញប្បទានរបស់ធនាគារពិភពលោក (សមាគមអភិវឌ្ឍន៍អន្តរជាតិ/IDA)។